GMAC

Garment Manufacturers Association in Cambodia

# សេចក្តីអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់

ដើម្បីគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានចេញបទបញ្ជាបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញទាំងមូលនិងក្រុងតាខ្មៅនៃខេត្តកណ្តាលចាប់ពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០២១។ បទបញ្ជាបិទខ្ទប់នេះតម្រូវឲ្យបិទអាជីវកម្មទាំងឡាយណាដែលមិនចាំបាច់ និងតម្រូវឲ្យប្រជាពលរដ្ឋត្រូវនៅក្នុងផ្ទះ និងអាចចេញក្រៅផ្ទះបានលុះត្រាតែមានករណីបន្ទាន់ឬចាំបាច់បំផុត។

វិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរមិនត្រូវបានចាត់ទុកថាជាវិស័យចាំបាច់ដែលត្រូវបើកដំណើរការប្រតិបត្តិការក្នុងអំឡុងការបិទខ្ទប់នេះទេ ហេតុដូច្នេះ យើងត្រូវតែបិទដំណើរ។ ការបិទខ្ទប់នេះក៏កំពុងបណ្តាលឲ្យមានការរាំងស្ទះដល់វិស័យពស្តុភារ ហើយយើងមិនអាចដឹកជញ្ជូនវត្ថុធាតុដើមនិង/ឬផលិតផលសម្រេចបានដោយសេរី។

សមាជិករបស់យើងមួយចំនួនដែលមិនស្ថិតនៅក្នុងតំបន់បិទខ្ទប់ក៏រងប៉ះពាល់ផងដែរដោយសារបុគ្គលិករបស់ពួកគេរស់នៅរាជធានីភ្នំពេញនិងក្រុងតាខ្មៅ ហើយត្រូវបានហាមឃាត់មិនឲ្យធ្វើដំណើរទៅធ្វើការ។ រោងចក្រទាំងនេះមិនអាចប្រតិបត្តិការដូចធម្មតា។ នេះបានបណ្តាលឲ្យមានការពន្យារពេលផលិតកម្ម ព្រមទាំងការខកខានមិនអាចបំពេញបានតាមកាលវិភាគដឹកជញ្ជូនទំនិញដែលបានព្រមព្រៀងគ្នា។

សមាគមសូមអំពាវនាវឲ្យមានការយោគយល់និងជួយសម្របសម្រួលសម្រាប់ស្ថានភាពដ៏លំបាកនេះ។ យើងទាំងអស់គ្នាត្រូវតែសហការនិងគោរពតាមការណែនាំរបស់រាជរដ្ឋាភិបាល និងត្រូវរួមគ្នាប្រយុទ្ធនឹងជំងឺកូវីដ-១៩។ សមាគមសូមជំរុញភាគីពាក់ព័ន្ធទាំងអស់មិនត្រូវដាក់ទោសទណ្ឌលើសមាជិករបស់សមាគមចំពោះស្ថានភាពដ៏លំបាកដែលលើសពីការគ្រប់គ្រងរបស់យើង។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០២១

**សមាគមរោងចក្រកាត់ដេរនៅកម្ពុជា**



តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Phum Trapeang Kul, Sangkat Kantouk, Khan Kambol, Phnom Penh, Cambodia.
Tel: (855)-23-301 181 | E-mail: info@gmac-cambodia.org | Website: www.gmac-cambodia.org